# មេរៀនទី ១១០: ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក

## ម៉ាថាយ ៣:១៣-១៧

**គោលបំណង៖** ព្រះយេស៊ូវគឺជាបុត្រារបស់ព្រះ។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៣:១៧** *"នោះមានឮសំឡេងចេញពីមេឃថា នោះជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះយេស៊ូវគឺអស្ចារ្យណាស់។ យើងគួរដឹងគុណដល់ព្រះរាជបុត្រានៃព្រះជារៀងរាល់ថ្ងៃ—សម្រាប់ការបង្ហាញផ្លូវដល់យើងទៅរកព្រះ និងភាពស្រស់ស្អាតនៃជីវិតរស់នៅសម្រាប់ទ្រង់។ ក្នុងជីវិតរបស់ទ្រង់នៅលើផែនដីនេះ ព្រះយេស៊ូវបានណែនាំមនុស្សឲ្យស្គាល់ព្រះ។ បន្ទាប់ពីព្រះយេស៊ូវបានឡើងទៅស្ថានសួគ៌ ពួកសិស្សរបស់ទ្រង់បានធ្វើតាមគំរូរបស់ព្រះអង្គ ហើយនាំអ្នកឯទៀតឲ្យជឿលើព្រះ និងបង្រៀនពីការលះបង់របស់ព្រះយេស៊ូវសម្រាប់យើង។ យើងគួរធ្វើតាមគំរូដូចគ្នា ដើម្បីដឹកនាំអ្នកដទៃឲ្យមានជំនឿដូចគ្នា។ តើអ្នកអាចធ្វើអ្វីខ្លះនៅថ្ងៃនេះ ដើម្បីជួយអ្នកដទៃឲ្យជឿលើព្រះយេស៊ូវ?

**ចំរៀង៖** ១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ២. ព្រះចាត់បុត្រា ៣. មានសុខសាន្តដូចទន្លេ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «គប់ទឹក»

**សម្ភារៈដែលត្រូវការ៖** កៅអីមួយ ប៉េងប៉ោង (សម្រាប់ច្រកទឹក)



**ចំណាំ៖** សូមលេងល្បែងនេះនៅខាងក្រៅ ពីព្រោះកុមារអាចទទឹក

១. សូមពន្យល់កុមារថាថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងនឹងរៀនពីការជ្រមុជទឹករបស់ព្រះយេស៊ូវ។ ដូច្នេះមុនពេលដែលយើងរៀនមេរៀននៅថ្ងៃនេះ យើងនឹងលេងល្បែងគប់ទឹកជាមួយគ្នា។



២. ឲ្យប៉េងប៉ោងទៅកុមារម្នាក់មួយ ហើយឲ្យពួកគេដាក់ទឹកនៅក្នុងប៉េងប៉ោងនោះ

៣. ជ្រើសរើសកុមារម្នាក់ ហើយឲ្យគេអង្គុយបែរខ្នងដាក់កុមារផ្សេងទៀត

៤. កុមារទាំងអស់និងប្តូរវេនគ្នាក្នុងការគប់ប៉េងប៉ោងទឹកនោះ ឲ្យត្រូវកុមារដែលអង្គុយលើកៅអី

៥. នៅពេលដែលប៉េងប៉ោងនោះគប់ត្រូវកុមារដែលអង្គុយនោះហើយ កុមារដែលអង្គុយនៅលើកៅអីត្រូវក្រោកឈរឡើងហើយទាយថា កុមារណាជាអ្នកគប់ប៉េងប៉ោងត្រូវគាត់នោះ។ ប្រសិនបើកុមារនោះទាយត្រូវ កុមារដែលជាអ្នកគប់ទឹកត្រូវមកអង្គុយលើកៅអីធ្វើជាអ្នកទាយវិញម្តង រួចបន្តលេងល្បែងនេះ។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងធ្វើអ្វីដើម្បីឱ្យឪពុកម្ដាយអ្នកមានមោទនភាព? តើអ្នកនឹងសម្អាតផ្ទះឬ? តើអ្នជួយកមើលថែបង ប្រុសឬបងស្រីរបស់អ្នកឬ? តើអ្នកស្ដាប់តាមអ្វីដែលពួកគេនិយាយទេ? ថ្ងៃនេះយើងនឹងរៀនអំពីព្រះយេស៊ូវ ដែលធ្វើឲ្យព្រះវរបិតារបស់ទ្រង់មានមោទនភាពយ៉ាងខ្លាំង!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវមានបងប្អូនជីដូនមួយឈ្មោះ យ៉ូហានបាទីស្ទ។ យ៉ូហានបានធ្វើដំណើរជុំវិញជនបទ ដើម្បីប្រាប់អ្នកឯទៀតអំពីព្រះ។ ពេលមនុស្សសម្រេចចិត្តជឿលើព្រះ យ៉ូហានបានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេ។ យ៉ូហាននឹងនាំពួកគេទៅក្នុងទន្លេយ័រដាន់ ហើយធ្វើពិធីជ្រមុជទឹកឲ្យពួកគេ។ វាជាផ្លូវមួយបង្ហាញថាពួកគេកំពុងលាងជម្រះអំពើបាបរបស់ពួកគេ ដោយចាប់ផ្ដើមជីវិតថ្មី និងជឿលើព្រះ។

ថ្ងៃមួយ ព្រះយេស៊ូវយាងទៅទន្លេយ័រដាន់។ ទ្រង់បានជួបបងប្អូនជីដូនមួយរបស់គាត់គឺយ៉ូហាននៅទីនោះ។ ព្រះយេស៊ូវបានសុំយ៉ូហានឲ្យធ្វើបុណ្យជ្រមុជទឹកដល់ទ្រង់ ប៉ុន្តែយ៉ូហានបាទីស្ទបានដឹងថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ជាម្នាក់ដែលគ្មានបាបសោះ។ ដូច្នេះ យ៉ូហានបាទីស្ទបាននិយាយថា គាត់គួរតែទទួលបុណ្យជ្រមុជទឹកដោយព្រះយេស៊ូវជំនួសវិញ។ ប៉ុន្តែព្រះយេស៊ូវបានប្រាប់យ៉ូហានថាវាជារឿងត្រឹមត្រូវ។ ដូច្នេះព្រះយេស៊ូវ និងយ៉ូហានបានដើរទៅក្នុងទន្លេ ហើយយ៉ូហានបានជ្រមុជទឹកឲ្យព្រះយេស៊ូវនៅទីនោះ។

ពេលព្រះយេស៊ូវយាងចេញពីទឹក ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះពីស្ថានសួគ៌មកដូចសត្វព្រាប។ នោះក៏មានសំឡេងពីលើមេឃថា៖ “នោះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់” នេះបង្ហាញពីព្រះត្រីឯក ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ព្រះវិញ្ញាណបរិសុទ្ធបានយាងមកដូចជាសត្វព្រាប ហើយព្រះដែលជាព្រះវរបិតាមានបន្ទូលពីស្ថានសួគ៌មក!

នៅពេលដែលព្រះមានបន្ទូលដូច្នេះ ព្រះយេស៊ូវមិនទាន់បានធ្វើអ្វីនៅឡើយទេ! ព្រះអង្គមិនទាន់បានចាប់ផ្ដើមចែកចាយព្រះបន្ទូលទេ។ ព្រះអង្គមិនបានព្យាបាលនរណាម្នាក់ទេ។ ព្រះអង្គមិនទាន់បានសុគតនៅលើឈើឆ្កាង ឬរស់ឡើងវិញទេ។ ដូច្នេះហេតុអ្វីបានជាព្រះវរបិតាពេញចិត្តនឹងព្រះយេស៊ូវ? ព្រះវរបិតាសព្វព្រះហឫទ័យនឹងព្រះយេស៊ូវ ដោយសារព្រះវរបិតាបានដឹងថា ព្រះយេស៊ូវនឹងស្ដាប់បង្គាប់ព្រះអង្គ។ ព្រះវរបិតាដឹងថាព្រះយេស៊ូវនឹងបង្ហាញសេចក្ដីស្រឡាញ់របស់ទ្រង់ដល់មនុស្សគ្រប់គ្នា។ ព្រះវរបិតាបានស្រឡាញ់ព្រះយេស៊ូវ ហើយព្រះយេស៊ូវក៏ស្រឡាញ់ទ្រង់ដែរ ។ នោះជាអ្វីដែលព្រះវរបិតាសព្វព្រះទ័យ!

ព្រះសព្វព្រះទ័យនឹងយើង ពេលយើងស្រឡាញ់ព្រះអង្គ! ព្រះអង្គពេញចិត្តនៅពេលយើងធ្វើអ្វីដែលទ្រង់ចង់បាន ប៉ុន្តែព្រះដឹងថាយើងមិនអាចល្អឥតខ្ចោះ ហើយទ្រង់ក៏មិនរំពឹងថាយើងនឹងល្អឥតខ្ចោះដែរ។ ហេតុនេះហើយបានជាព្រះបានចាត់ព្រះយេស៊ូវជាបុត្រដ៏ល្អឥតខ្ចោះរបស់ទ្រង់មកឯយើង។ នៅពេលដែលយើងជឿលើព្រះយេស៊ូវ និងអ្វីដែលទ្រង់បានធ្វើសម្រាប់យើងនៅលើឈើឆ្កាង នោះព្រះទ្រង់ទតឃើញព្រះយេស៊ូវនៅពេលដែលទ្រង់សម្លឹង

មកយើង! ហើយនោះធ្វើឱ្យព្រះមើលឃើញយើងល្អឥតខ្ចោះ។ ហេតុនេះហើយបានជាយើងថ្វាយបង្គំព្រះយេស៊ូវជាព្រះរាជបុត្រារបស់ព្រះ!

**៦. សំនួរពិភាក្សា**

១. ហេតុអ្វីបានជាយ៉ូហានបាទីស្ទធ្វើដំណើរជុំវិញជនបទ? *ប្រាប់មនុស្សអំពីព្រះ*

២. តើយ៉ូហានបាទីស្ទបានធ្វើអ្វីសំរាប់មនុស្សដែលមកជឿលើព្រះ? *គាត់បានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេនៅទន្លេយ័រដាន់*

៣. ហេតុអ្វីបានជាយ៉ូហានបាទីស្ទព្យាយាមរារាំងព្រះយេស៊ូវមិនឲ្យទទួលការជ្រមុជទឹកពីគាត់? *ដោយសារគាត់បានដឹងថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះដែលគ្មានបាប*

៤. តើព្រះយេស៊ូវជានរណា ហើយហេតុអ្វីយើងថ្វាយបង្គំទ្រង់? *ទ្រង់ជាព្រះរាជបុត្រានៃព្រះ*

**៧. ល្បែងកំសាន្ត «បូមទឹកដាក់ដប»**

**សម្ភារៈដែលត្រូវការ៖** ធុងទឹកធំ២ ស្លឹកចេកឬក៏ស្លឹកឈូក ដបទឹកសុទ្ធ១,៥លីត្រ ២ដប



១. ដាក់ទឹកឲ្យពេញក្នុងធុងធំៗទាំង២នោះ ហើយដាក់វានៅចុងថ្នាក់រៀន

២. ចែកកុមារជា២ក្រុម ឲ្យដបទឹកសុទ្ធ១,៥លីត្រទៅក្រុមនីមួយៗ រួចដាក់វានៅចុងម្ខាងទៀតនៃថ្នាក់រៀន

៣. ឲ្យស្លឹកចេកឬក៏ស្លឹកឈូកទៅកុមារគ្រប់គ្នាៗ ហើយឲ្យពួកគេព្យាយាមបត់ស្លឹកនោះ ឲ្យក្លាយជាកន្ទោងឬជាអ្វីក៏បានដែលគេអាចដួសទឹកបាន

៤. កុមារទាំងអស់ត្រូវប្តូរវេនគ្នាក្នុងការរត់ទៅដួសទឹកនៅក្នុងធុងធំនោះ ហើយរត់យកវាមកដាក់ចូលក្នុងដបទឹកសុទ្ធទទេ ដែលនៅចុងម្ខាងទៀតនៃថ្នាក់រៀន។ ក្រុមណាដែលអាចយកទឹកមកដាក់ពេញដបមុន ក្រុមនោះជាអ្នកឈ្នះ។



**៨. ខគម្ពីរចងចាំ ម៉ាថាយ ៣:១៧**

**៩. ហត្ថកម្ម ផាត់ពណ៌ - «ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក»**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះយេស៊ូបុណ្យជ្រមុជទឹក



សូមសរសេរខគម្ពីរចងចាំ: ______________________

______________________________________________

______________________________________________

______________________________________________